**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Apr-2015, 09:23
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសារធារណៈ**:មួយ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ:/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបាន**ពិនិត្យ:

**ហត្ថលេខា:**

---

**សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកសម្រង់នៃសៀវភៅ "BROTHERS IN ARMS" ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ អនុលោមតាមវិធាន៨៧(៣) & ៨៧(៤) នៃវិធានផ្ទៃក្នុង**

---

**<u>អ្នកដាក់ឯកសារ:</u>**

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**<u>អ្នកទទួលឯកសារ:</u>**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Marie GUIRAUD

**<u>ចម្លងជូន:</u>**

**ជនជាប់ចោទ:**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**មេធាវីប្រចាំការ:**

លោកស្រី ទូច វលល័ក្ស

លោក Calvin SAUNDERS

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន៨៧(៣) & ៨៧(៤) នៃវិធានផ្ទៃក្នុង និងការសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាសូមដាក់សំណើនេះ ដោយសុំឱ្យទទួលយកជាភ័ស្តុតាងនៃសម្រង់ពីសៀវភៅមួយរបស់សាស្ត្រាចារ្យ Andrew Mertha ដែលមានចំណងជើងថា "Brothers in Arms: Chinese Aid to the Khmer Rouge, 1975-1979" ("សៀវភៅ")។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានដាក់សំណើមួយដោយបានស្នើឱ្យទទួលយកសៀវភៅនេះជាភ័ស្តុតាង អនុលោមតាមវិធាន៨៧(៣) & ៨៧(៤) នៃវិធានផ្ទៃក្នុង[1]។

3. នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ខៀវ សំផន បានឆ្លើយតបដោយជំទាស់នឹងសំណើនេះ[2]។

4. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផ្ទាល់មាត់ដោយបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់សំណើថ្មីមួយ ដោយកំណត់អត្តសញ្ញាណសម្រង់ពីសៀវភៅនោះ ដែលខ្លួនមានបំណងចង់សុំឱ្យទទួលយក[3]។

## III. វិធាន៨៧(៣) & ៨៧(៤) នៃវិធានផ្ទៃក្នុង

5. អមដោយ **ឧបសម្ព័ន្ធ ក** ភ្ជាប់ទៅជាមួយនឹងការដាក់ឯកសារនេះ គឺសម្រង់ពីសៀវភៅនេះ ដែលសហព្រះរាជអាជ្ញាចង់ឱ្យទទួលយក។ និយាយឱ្យចំ សហព្រះរាជអាជ្ញាចង់ឱ្យទទួលយកកថាខណ្ឌទីពីរទាំងមូលត្រង់ទំព័រទី៧ ចាប់ពី "But the domestic politics…" តទៅ ("សម្រង់")។ សម្រង់នេះបំពេញបាននូវលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយក ស្របតាមវិធាន៨៧(៣)។ សម្រង់នេះមានសម្ភារៈដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ និងជាពិសេសទៅនឹងទីតាំងឧក្រិដ្ឋកម្មសហករណ៍ត្រាំកក់។ សម្រង់នេះ និយាយពីដំណើរមកកាន់កម្ពុជាប្រជាធិបតេយ្យ

---

[1] **E342** សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកសៀវភៅដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង, ៣ មីនា ២០១៥។

[2] **E342/1** ចម្លើយតបទៅនឹងសំណើសហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដាក់បញ្ចូលក្នុងកិច្ចពិភាក្សាដេញដោលនូវសៀវភៅមួយក្បាលពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងសំណុំរឿង០០២/០២ អនុលោមតាមវិធាន ៨៧ (៣) និង ៨៧ (៤) នៃវិធានផ្ទៃក្នុង, ១៣ មីនា ២០១៥។

[3] **E1/285.1** ប្រតិចារឹក, ៣១ មីនា ២០១៥ [10.03.05]។

របស់ឥស្សរជនចិនមួយរូប គឺលោក Chen Yonggui ដែលគាត់ជាប្រធានឃុំគំរូចិនមួយរូបផងដែរ។ សម្រង់នេះរៀបរាប់អំពីកិច្ចប្រជុំនានារបស់គាត់ជាមួយមន្ត្រីកម្ពុជាប្រជាធិបតេយ្យខុសៗគ្នា និងដំណើរទស្សនកិច្ចរបស់គាត់ទៅស្រុកត្រាំកក់ និងឃុំគំរូលាយបូ (Leay Bo)។

6. អ្នកនិពន្ធសៀវភៅនេះ គឺជាអ្នកដែលទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតខាងវិទ្យាសាស្ត្រនយោបាយពីសកលវិទ្យាល័យ Michigan និងជាសាស្ត្រាចារ្យមួយរូបរបស់រដ្ឋាភិបាល នៅសកលវិទ្យាល័យ Cornell University ជាទីដែលគាត់មានជំនាញខាងនយោបាយចិន និងកម្ពុជា[4]។

7. វិធាន៨៧(៤)នៃវិធានផ្ទៃក្នុងចែងថាភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងថ្មីដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលនៃការចាប់ផ្តើមជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សម្រាប់សំណុំរឿង០០២/០២ ការបើកសវនាការបានកើតឡើងក្នុងខែមិថុនា ឆ្នាំ២០១១[5]។ សៀវភៅនេះមិនទាន់បានផ្សព្វផ្សាយនៅឡើយទេ រហូតដល់ឆ្នាំ២០១៤ ដូច្នេះសម្រង់ដែលពាក់ព័ន្ធមិនទាន់អាចរកបាននៅមុនការបើកសវនាការឡើយ។

8. ដូចបានបង្ហាប់ ទោះបីសហព្រះរាជអាជ្ញា បានកំណត់អត្តសញ្ញាណសម្រង់ដែលខ្លួនមានបំណងសុំឲ្យទទួលយកក្នុងពេលបច្ចុប្បន្នក៏ដោយ ក៏សហព្រះរាជអាជ្ញានឹងកាន់តែពេញចិត្ត ហើយក៏ស្របនឹងការអនុវត្តកន្លងមកផងដែរ ដែលសៀវភៅទាំងមូលត្រូវបានទទួលយក។ សហព្រះរាជអាជ្ញាសូមរំលឹកថា នៅក្នុងអំឡុងនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២ ភាគីនានាពីដំបូងធ្លាប់បានអនុវត្តដោយស្នើសុំដាក់សម្រង់ពីសៀវភៅនានាទៅក្នុងសំណុំរឿង។ ប្រព័ន្ធនេះ ក្រោយមកត្រូវបានរកឃើញថាពិបាកប្រើដោយហេតុថា វាចេះតែមានការស្នើសុំឲ្យទទួលយកសម្រង់ជាច្រើនពីសៀវភៅដដែលៗជាបន្តបន្ទាប់ ដែលជាហេតុធ្វើឲ្យមានផ្នែកខុសៗគ្នាជាច្រើននៃសៀវភៅតែមួយ មាននៅក្នុងសំណុំរឿងដែលមានលេខឯកសារខុសៗគ្នា។ ហេតុដូច្នេះ ប្រព័ន្ធនេះក្រោយមកត្រូវបានបោះបង់ចោល ដោយបំពេញមកវិញតាមរយៈការទទួលយកសៀវភៅទាំងមូលដាក់បញ្ចូលទៅក្នុងសំណុំរឿង និងបន្ទាប់មកអនុញ្ញាតឲ្យភាគីនានាស្នើសុំបកប្រែផ្នែកដែលខ្លួនយល់ថាពាក់ព័ន្ធ។

## IV. ដំណោះស្រាយដែលស្នើឡើង

9. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យ៖

[4] *សូមមើល* http://government.arts.cornell.edu/faculty/mertha/ (ចូលមើលចុងក្រោយ ២ មីនា ២០១៥)។

[5] **E307/1** សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)", ១១ មិថុនា ២០១៤។ **E307/1/2** សេចក្តីសម្រេចលើសំណើសុំរួមឲ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង, ២១ តុលា ២០១៤, កថាខណ្ឌ១០។

ក. ដាក់សៀវភៅទាំងមូល[6] ទៅក្នុងសំណុំរឿង; ហើយ

ខ. ទទួលយកសម្រង់ ដែលបានដាក់ភ្ជាប់ទៅជាមួយជា **ឧបសម្ព័ន្ធ ក** ជាភស្តុតាងក្នុងសំណុំរឿង០០២/០២ អនុលោមតាមវិធាន៨៧(៣) & ៨៧(៤) នៃវិធានផ្ទៃក្នុង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |

[6] **E342.1** Brothers in Arms: Chinese Aid to the Khmer Rouge 1975-1979, ឆ្នាំ២០១៤។